# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

++++++++++++

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី ០១ មេសា ២០២០ រវាង

**លោក លូ ម៉េង** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០១៥៣៥៦៣(០១) ដែលមានតួនាទីជាអគ្គនាយក និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **វើលដ៍ ដាយនីង លីមីធិត** ដែលមានអាសយដ្ឋានស្ថិតនៅ ផ្ទះលេខ២៨ ផ្លូវ សម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌទួលចំការមន រាជធានីភ្នំពេញ

និង

**លោកស្រី ចាន់ ស៊ី** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១០៥៧៩០០ ដែលមានតួនាទីជា នាយកគ្រប់គ្រងទូទៅ និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

**មាត្រា១៖ រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖**

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ បង្កដោយវីរុស កូវីដ១៩។

**មាត្រា២៖ ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជក កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

**មាត្រា៣៖ កាលបរិច្ឆេទចូលបម្រើការងារវិញ**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់ និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព៕

| | |
|---|---|
| **តំណាងភាគីនិយោជក** | **តំណាងភាគីនិយោជិក** |
| **លោក លូ ម៉េង** | **លោកស្រី ចាន់ ស៊ី** |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធិត World Dining Limited KINGDOM OF CAMBODIA